( បកប្រែក្រៅផ្លូវការ )

# កិច្ចព្រមព្រៀង

# រវាង

# ព្រះរាជាណាចក្រកម្ពុជា

# និង

# ជប៉ុន

# ស្តីពី

# សេរីភាវូបនីយកម្ម ការជំរុញ និង ការការពារវិនិយោគ

꧁❊꧂

***ព្រះរាជាណាចក្រកម្ពុជា និង ជប៉ុន :***

ដោយមានបំណងជម្រុញឱ្យកាន់តែប្រសើរនូវការវិនិយោគ ដើម្បីពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ

ក្នុងគោលបំណងបង្កើតនូវល័ក្ខខ័ណ្ឌអនុគ្រោះ សំរាប់កិច្ចដំណើរការវិនិយោគរបស់អ្នកវិនិយោគនៃប្រទេសមួយ នៅក្នុងតំបន់នៃប្រទេសមួយទៀត

ដោយទទួលស្គាល់ពីសារៈសំខាន់នៃការវិវឌ្ឍន៍ដំណើរការសេរីភាវូបនីយកម្មវិនិយោគ ដែលនឹងនាំមកនូវគំនិតផ្តួចផ្តើមថែមទៀតរបស់អ្នកវិនិយោគ និង លើកកំពស់ វិបុលភាព នៅក្នុងប្រទេសទាំងពីរ

ដោយទទួលស្គាល់ពីការរីកលូតលាស់នៃទំនាក់ទំនងសេដ្ឋកិច្ច នៅក្នុងចំណោមសមាជិកសមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ជាទូទៅ ដែលនឹងរួមចំណែកដល់ការជម្រុញការវិនិយោគ

ដោយទទួលស្គាល់ថា គោលដៅទាំងនេះអាចត្រូវស័រេចបាន ដោយពុំមានការបន្ធូរបន្ថយផ្នែកសុខភាព សុវត្ថិភាព និងវិធានការបរិស្ថាននៃការអនុវត្តជាទូទៅនោះឡើយ និង

ដោយទទួលស្គាល់នូវសារៈសំខាន់នៃទំនាក់ទំនងកិច្ចសហប្រតិបត្តិការ រវាងការងារ និងការគ្រប់គ្រងក្នុងការជម្រុញការវិនិយោគរវាងប្រទេសទាំងពីរ។

***ភាគីទាំងពីរបានព្រមព្រៀងដូចខាងក្រោមៈ***

## មាត្រា ១

គោលបំណងនៃកិច្ចព្រមព្រៀងនេះៈ

(១) ពាក្យ " វិនិយោគ "គឺសំដៅលើទ្រព្យសម្បត្តិគ្រប់ប្រភេទដែលជាកម្មសិទ្ធិ ឬ គ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោលរបស់អ្នកវិនិយោគរួមមានៈ

(ក) សហគ្រាស

(ខ) ភាគហ៊ុន ហ៊ុន ឬការចូលរួមជាភាគហ៊ុនផ្សេងៗទៀតនៅក្នុងសហគ្រាស រួមបញ្ចូលទាំងសិទ្ធិដែលបានមកពីការចូលរួមនោះ

(គ) ប័ណ្ណជានា ប័ណ្ណកាតព្វកិច្ច ប្រាក់កម្ចី និងទ្រង់ទ្រាយផ្សេងៗទៀតនៃបំណុល រួមបញ្ចូលទាំងសិទ្ធិដែលបានមកពីការចូលរួមនោះ

(ឃ) សិទ្ធិដែលកំណត់ក្នុងកិច្ចសន្យារួមបញ្ចូលទាំងកិច្ចសន្យាណែនាំអនុវត្តន៍គម្រោងសាងសង់រួចជាស្រេច ការសាងសង់ ការគ្រប់គ្រង ការផលិត ឬ កិច្ចសន្យា បែងចែកផលចំណូល។

(ង) ការទាមទារប្រាក់ និង ការទាមទារឱ្យបំពេញកាតព្វកិច្ចដោយផ្អែកទៅតាមកិច្ចសន្យាដែលមានតំលៃហិរញ្ញវត្ថុ។

(ច) កម្មសិទ្ធិបញ្ញា រួមបញ្ចូលទាំងសិទ្ធិចំលង និងសិទ្ធិដែលពាក់ព័ន្ធផ្សេងៗទៀត សិទ្ធិលើប្រកាសនីយបត្រតក្កកម្ម និងសិទ្ធិពាក់ព័ន្ធទៅនឹងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ពាណិជ្ជសញ្ញា គំនូរឧស្សាហកម្ម គំនូរព្រាង នៃដំណើរជុំវិញបញ្ចូលគ្នា ប្រភេទថ្មីៗនៃរុក្ខជាតិ ពាណិជ្ជនាម ការបង្ហាញពីប្រភព ឬ ការកំណត់ទីតាំងភូមិសាស្ត្រ និង ការរក្សាការសម្ងាត់នៃព័ត៌មាន។

(ឆ) សិទ្ធិដែលកំណត់ ដោយច្បាប់ បទប្បញ្ញត្តិ ឬ ដោយកិច្ចសន្យាដូចជាសម្បទាន អាជ្ញាប័ណ្ណ ការផ្តល់អំណាច និងការអនុញ្ញាត រួមបញ្ចូលទាំងសិទ្ធិលើការរុករក និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ និង

(ជ) រាល់ទ្រព្យរូបីយ៍ និង អរូបីយ៍ ចលនទ្រព្យ និងអចលនទ្រព្យ និងសិទ្ធិពាក់ព័ន្ធដទៃទៀតដូចជា ការជួល ការបញ្ចាំ ការបញ្ចាំចលនវត្ថុ និងការសន្យាធានា។

ការវិនិយោគរួមបញ្ចូលទាំងទិន្នផលដែលបានមកពីការធ្វើវិនិយោគជាពិសេសប្រាក់ចំណេញ ការប្រាក់ ចំណេញមូលធន ប្រាក់ចំណេញនៃភាគហ៊ុន សួយសារ និងកំរៃ ។ ការប្តូរទ្រង់ទ្រាយនៃទ្រព្យសម្បត្តិដែលបានវិនិយោគ មិនមានឥទ្ធិពលទៅលើចរឹកនៃការវិនិយោគដែលបានផ្តល់ជូនឡើយ។

(២) ពាក្យ "វិនិយោគិននៃភាគីជាប់កិច្ចសន្យា" មានន័យថា:

(ក) រូបវ័ន្តបុគ្គល ដែលមានសញ្ជាតិនៃភាគីជាប់កិច្ចសន្យាដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។

(ខ) សហគ្រាសនៃភាគីជាប់កិច្ចសន្យា។

សាខារបស់សហគ្រាសដែលមិនមែនជាភាគីជាប់កិច្ចសន្យាដែលមានទីតាំងស្ថិតនៅក្នុងទឹកដីរបស់ភាគីជាប់កិច្ចសន្យា មិនត្រូវបានចាត់ទុកថាជាអ្នកវិនិយោគនៃភាគីចុះកិច្ចសន្យាឡើយ។

(៣) ពាក្យ "សហគ្រាស" គឺ

(ក) "ភាពធ្វើជាម្ចាស់" ដោយអ្នកវិនិយោគ ប្រសិនបើភាគហ៊ុនលើសពី ៥០% ឡើងទៅនៅក្នុងសហគ្រាសកាន់កាប់ដោយអ្នកវិនិយោគ និង

(ខ) "ការត្រួតត្រា" ដោយអ្នកវិនិយោគ ប្រសិនបើអ្នកវិនិយោគមានអំណាចក្នុងការចាត់តាំងភាគច្រើនក្នុងចំណោមនាយកសហគ្រាសរបស់ខ្លួន ឬ បើមិនដូចនេះទេ មានសិទ្ធិស្របច្បាប់ក្នុងការដឹកនាំដោយផ្ទាល់នូវសកម្មភាពរបស់សហគ្រាស។

(៤) ពាក្យ"សហគ្រាសរបស់ភាគីជាប់កិច្ចសន្យា" មានន័យថា នីតិបុគ្គល ឬ អង្គភាព ដែលបង្កើត ឬរៀបចំឡើងដោយច្បាប់ ឬបទប្បញ្ញត្តិនៃភាគីជាប់កិច្ចសន្យាដើម្បីទិសដៅរក ឬពុំរកផលចំណេញ និងទោះបីម្ចាស់ ឬអ្នកត្រួតត្រាសហគ្រាសនោះជាឯកជន ឬជារដ្ឋាភិបាលក៏ដោយ រួមបញ្ចូលទាំង សាជីវកម្ម ឯកាធិកម្ម សហកម្មសិទ្ធិ ឯកកម្មសិទ្ធិ សម្ព័ន្ធអាជីវកម្ម សមាគម អង្គការ ក្រុមហ៊ុន ឬសាខា។

(៥) ពាក្យ "តំបន់" មានន័យ ចំពោះភាគីជាប់កិច្ចសន្យា (ក) ទឹកដីនៃភាគីជាប់កិច្ចសន្យានោះ និង (ខ) តំបន់សេដ្ឋកិច្ចពិសេស និង ឈូងសមុទ្រ ដែលភាគី

ជាប់កិច្ចសន្យាមានសិទ្ធិអំណាចគ្រប់គ្រងអធិបតេយ្យភាព និង កាតព្វកិច្ចគ្រប់គ្រងតាមផ្លូវច្បាប់ ដោយអនុលោមទៅតាមច្បាប់អន្តរជាតិ។

(៦) ពាក្យ"កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក" មានន័យសំដៅ លើកិច្ចព្រមព្រៀង Marrakesh (Marrakesh Agreement) ដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក នៅ Marrakesh នាថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៤ ដែលអាចត្រូវបានធ្វើវិសោធនកម្ម។

## មាត្រា ២

១ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវផ្តល់ដល់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និងការវិនិយោគរបស់គេនៅក្នុងតំបន់របស់ខ្លួននូវ ប្រព្រឹត្តិកម្មវិនិយោគ មិនតិចជាងអ្វីដែលខ្លួនបានយល់ព្រមក្នុងកាលៈទេសៈដូចគ្នា ទៅឱ្យអ្នកវិនិយោគរបស់ខ្លួន និង ការវិនិយោគរបស់អ្នកវិនិយោគនោះ សំរាប់ការបង្កើត ការទិញយក ការពង្រីក ប្រតិបត្តិការ ការគ្រប់គ្រង ការថែរក្សា ការប្រើប្រាស់ ការអាស្រ័យផល និងការលក់ ឬការចាត់ចែងវិនិយោគផ្សេងៗទៀត (ចាប់ពីពេលនេះតទៅហៅថា "សកម្មភាពវិនិយោគ") ។

២ ថ្វីបើមានកំណត់ក្នុងកថាខ័ណ្ឌទី ១ ក៏ដោយ ភាគីជាប់កិច្ចសន្យានិមួយៗ អាចដាក់ចេញនូវទម្រង់ពិសេស ដែលពាក់ព័ន្ធទៅនឹងសកម្មភាពវិនិយោគរបស់អ្នកវិនិយោគនៃភាគីចុះកិច្ចសន្យាម្ខាងទៀតនៅក្នុងតំបន់របស់ខ្លួន ក្នុងករណីទម្រង់ពិសេសនោះមិនធ្វើឱ្យប៉ះពាល់ដល់ខ្លឹមសារនៃសិទ្ធិរបស់អ្នកវិនិយោគនោះ ក្រោមការកំណត់នៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ៣

ភាគីចុះកិច្ចសន្យានិមួយៗ ត្រូវផ្តល់នៅក្នុងតំបន់របស់ខ្លួន នូវការយល់ព្រមផ្តល់ដល់អ្នកវិនិយោគនៃភាគីចុះកិច្ចសន្យាម្ខាងទៀត និង ការវិនិយោគរបស់គេនូវប្រព្រឹត្តិកម្មដែលមានអំណោយផល មិនតិចជាងប្រព្រឹត្តិកម្មដែលបានយល់ព្រមផ្តល់នៅក្នុងកាលៈទេសៈដូចគ្នាឱ្យទៅអ្នកវិនិយោគនៃភាគីដែលមិនជាប់កិច្ចសន្យា ឬ ការវិនិយោគរបស់ពួកគេ ដែលទាក់ទងដល់សកម្មភាពវិនិយោគ ។

## មាត្រា ៤

១ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវផ្តល់នូវការយល់ព្រមឱ្យការវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវប្រព្រឹត្តិកម្មស្របតាមច្បាប់អន្តរជាតិ រួមបញ្ចូលទាំងប្រព្រឹត្តិកម្មដែលត្រឹមត្រូវ និង យុត្តិធម៌ ព្រមទាំងកិច្ចការពារ និង សន្តិសុខយ៉ាងពេញលេញ។

២ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវពិនិត្យមើលនូវបណ្តាកាតព្វកិច្ចផ្សេងៗដែលអាចមានទំនាក់ទំនងចំពោះការវិនិយោគរបស់អ្នកវិនិយោគ នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត។

## មាត្រា ៥

ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវផ្តល់ការយល់ព្រមនៅក្នុងតំបន់របស់ខ្លួនទៅឱ្យអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវប្រព្រឹត្តិកម្ម មិនតិចជាងប្រព្រឹត្តកម្ម ដែលខ្លួនបានផ្តល់ការយល់ព្រមនៅក្នុងកាលៈទេសៈដូចគ្នាទៅឱ្យអ្នកវិនិយោគរបស់ខ្លួន ឬ អ្នកវិនិយោគនៃភាគីមិនជាប់កិច្ចសន្យា ទាក់ទងទៅនឹងការដាក់បណ្តឹងទៅតុលាការយុត្តិធម៌ និង តុលាការរដ្ឋបាល ព្រមទាំងភ្នាក់ងារយុត្តាធិការគ្រប់កម្រិត នូវសិទ្ធិរបស់អ្នកវិនិយោគ ទាំងក្នុងករណីជាដើមចោទ និង ជាចុងចោទ ។

## មាត្រា ៦

១ មិនមានភាគីជាប់កិច្ចសន្យាណាមួយអាចដាក់កំហិត ឬ ឱ្យអនុវត្តដូចជាល័ក្ខខ័ណ្ឌសំរាប់សកម្មភាពវិនិយោគរបស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនៅក្នុងតំបន់របស់ខ្លួននូវតម្រូវការណាមួយដូចតទៅ :

(ក) កំណត់នូវកម្រិត ឬ ភាគរយក្នុងការនាំចេញទំនិញ ឬ សេវាកម្ម

(ខ) សំរេចឱ្យបាននូវកម្រិតកំណត់ ឬ ភាគរយណាមួយក្នុងការប្រើប្រាស់នូវវត្ថុធាតុដើមក្នុងស្រុក

(គ) ទិញ ប្រើប្រាស់ ឬ ផ្គត់ផ្គង់នូវទំនិញដែលបានផលិត ឬ សេវាកម្មដែលបានផ្តល់នៅក្នុងតំបន់ ឬ ទទួលទិញទំនិញ ឬ ទទួលសេវាកម្មពីរូបវ័ន្តបុគ្គល ឬ នីតិបុគ្គល ឬ អង្គភាពផ្សេងទៀតនៅក្នុងតំបន់

(ឃ) ធ្វើការភ្ជាប់តាមវិធីណាក៏ដោយនូវទំហំ ឬ តំលៃនៃការនាំចូលទៅនឹងទំហំ ឬ តំលៃនៃការនាំចេញ ឬ ទៅនឹងបរិមាណនៃការនាំចូលរូបិយប័ណ្ណបរទេស ដែលមានទំនាក់ទំនងទៅនឹងការវិនិយោគនៃអ្នកវិនិយោគនោះ ។

(ង) ដាក់កំហិតលើការលក់ទំនិញ ឬ សេវាកម្មនៅក្នុងតំបន់ដែលការវិនិយោគរបស់អ្នកវិនិយោគនោះធ្វើការផលិត ឬ ផ្តល់ដោយភ្ជាប់ការលក់ ដូចនេះតាមវិធីណាក៏ដោយទៅនឹងទំហំ ឬ តម្លៃនៃការនាំចេញ ឬ ទៅនឹងចំណូលនៃរូបិយប័ណ្ណបរទេស ។

(ច) តែងតាំងជាប្រតិបត្តិករ អ្នកគ្រប់គ្រង ឬ សមាជិក នៃក្រុមប្រឹក្សាភិបាល នូវបុគ្គលដែលមានសញ្ជាតិជាពិសេសណាមួយ

(ឆ) ផ្ទេរបច្ចេកវិទ្យា ដំណើរការផលិតកម្ម ឬ ចំណេះដឹងជាទ្រព្យសម្បត្តិផ្សេងទៀត ទៅឱ្យ រូបវ័ន្ត ឬ នីតិបុគ្គល ឬ អង្គភាពណាផ្សេងទៀតនៅក្នុងតំបន់របស់ខ្លួន លើកលែងតែនៅពេលដែលតម្រូវការ (i) បានកំណត់ ឬ ដាក់ឱ្យអនុវត្តន៍ដោយតុលាការ, តុលាការរដ្ឋបាល ឬ អាជ្ញាធរមានសមត្ថកិច្ច ដើម្បីជាសំណងជួសជុលចំពោះការចោទប្រកាន់គ្មានភស្តុតាងពាក់ព័ន្ធការរំលោភបំពានទៅនឹងច្បាប់ប្រកួតប្រជែង ឬ (ii) ពាក់ព័ន្ធទៅនឹងការផ្ទេរកម្មសិទ្ធិបញ្ញាដែលបានប្រកាន់យកតាមរូបភាពដែលមានសង្គតភាពទៅនឹងកិច្ចព្រមព្រៀងនៃកម្មសិទ្ធិបញ្ញាស្តីពីទិដ្ឋភាពទាក់ទងទៅនឹងពាណិជ្ជកម្មនៅក្នុងឧបសម្ព័ន្ធ ១C នៃកិច្ចព្រមព្រៀង WTO (ចាប់ពីពេលនេះតទៅហៅថា “កិច្ចព្រមព្រៀង TRIPS”)។

(ជ) ដាក់ទីស្នាក់ការកណ្តាលរបស់អ្នកវិនិយោគនោះ សំរាប់ធ្វើជាភូមិភាគមួយដោយឡែក ឬ ទីផ្សារពិភពលោកនៅក្នុងតំបន់របស់ខ្លួន។

(ឈ) ជួលនូវជនជាតិរបស់ខ្លួនតាមចំនួន ឬ តាមភាគរយកំណត់

(ញ) បំពេញឱ្យបាននូវកម្រិតកំណត់ ឬ តម្លៃណាមួយនៃការស្រាវជ្រាវ និង ការអភិវឌ្ឍន៍នៅក្នុងតំបន់របស់ខ្លួន ឬ

(ដ) ផ្គត់ផ្គង់នូវទំនិញមួយ ឬ ច្រើនដែលអ្នកវិនិយោគផលិត ឬ សេវាកម្មដែលអ្នកវិនិយោគផ្តល់ពីតំបន់ជាទឹកដីរបស់ភាគីជាប់កិច្ចសន្យា ទៅឱ្យភូមិភាគដោយឡែក ឬ ទៅលើទីផ្សារពិភពលោក។

២ បទប្បញ្ញត្តិរបស់កថាខ័ណ្ឌ ១ ខាងលើ មិនរារាំងឱ្យភាគីជាប់កិច្ចសន្យាណាមួយទទួលយកនូវល័ក្ខខ័ណ្ឌក្នុងការទទួលបាន ឬ បន្តទទួលនូវអត្ថប្រយោជន៍ដែលពាក់ព័ន្ធទៅនឹងសកម្មភាពវិនិយោគនៅក្នុងតំបន់របស់ខ្លួននៃអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត ក្នុងការបំពេញនូវតម្រូវការណាមួយ ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ (ឆ) ដល់ (ឈ) ខាងលើនោះឡើយ ។

## មាត្រា ៧

១ មាត្រា ២ - ៣ និង ៦ មិនអនុវត្តន៍ចំពោះ :

(ក) វិធានការមានស្រាប់មិនសមស្របណាមួយ ដែលត្រូវបានរក្សាទុកដែលមានចែងក្នុងកម្មវិធីនៃឧបសម្ព័ន្ធ I ដូចតទៅ:

(I) រដ្ឋបាលកណ្តាលនៃភាគីជាប់កិច្ចសន្យា ឬ

(II) ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ឬ ខេត្តនៃប្រទេសជប៉ុន

(ខ) វិធានការមានស្រាប់មិនសមស្របណាមួយ ដែលត្រូវបានរក្សាទុកដោយរដ្ឋាភិបាលមូលដ្ឋានក្រៅពី ខេត្តរបស់កម្ពុជា ឬ ខេត្តរបស់ជប៉ុន ដូចមានចែងនៅក្នុងអនុកថាខ័ណ្ឌ (ក) (II) ។

(គ) ការបន្ត ឬ ការរៀបចំជាថ្មីឡើងវិញជាបន្ទាន់នូវវិធានការមិនសមស្របណាមួយ ដោយអនុលោមទៅនឹងអនុកថាខ័ណ្ឌ (ក) និង (ខ) ឬ

(ឃ) ការធ្វើវិសោធនកម្ម ឬ ការកែប្រែនូវវិធានការមិនសមស្របណាមួយដោយអនុលោមទៅនឹងអនុកថាខ័ណ្ឌ (ក) និង (ខ) ក្នុងករណីការធ្វើវិសោធនកម្ម ឬ ការកែប្រែនោះមិនបានបន្ថយនូវភាពសមស្របនៃវិធានការដែលមានស្រាប់មុនការធ្វើវិសោធនកម្ម ឬការកែប្រែជាមួយនឹងមាត្រា ២ - ៣ និង ៦ ទេនោះ។

២ មាត្រា ២ - ៣ និង ៦ មិនអនុវត្តចំពោះវិធានការណាមួយដែលភាគីជាប់កិច្ចសន្យាបានអនុម័ត ឬប្រកាន់យកចំពោះវិស័យ អនុវិស័យ ឬសកម្មភាពដែលបានកំណត់នៅក្នុងកម្មវិធីនៃឧបសម្ព័ន្ធ II នោះទេ។

៣ មិនមានភាគីជាប់កិច្ចសន្យាណាមួយ ក្រោមវិធានការណាមួយក៏ដោយដែលខ្លួនបាន អនុម័តក្រោយថ្ងៃចូលជាធរមាននៃកិច្ចព្រមព្រៀង និង គ្របដណ្តប់ដោយកម្មវិធីនៃ ឧបសម្ព័ន្ធ (II) នេះ តម្រូវឱ្យអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដោយផ្អែក ទៅលើហេតុផលសញ្ជាតិរបស់គេធ្វើការលក់ ឬ បើមិនដូចនេះទេ ចាត់ចែងសកម្មភាព វិនិយោគដែលមានស្រាប់របស់គេ ឱ្យទៅជាវិធានការដែលមានប្រសិទ្ធភាពបានឡើយ។

៤ ក្នុងករណីដែលភាគីជាប់កិច្ចសន្យាធ្វើវិសោធនកម្ម ឬ កែប្រែនូវវិធានការដែលមានស្រាប់ មិនសមស្របណាមួយដែលមានកំណត់នៅក្នុងកម្មវិធីនៃឧបសម្ព័ន្ធ (I) របស់ខ្លួន ឬ នៅពេលដែលភាគីជាប់កិច្ចសន្យាអនុម័តនូវវិធានការថ្មីណាមួយ ឬ វិធានការកំហិត បន្ថែមទៀតចំពោះវិស័យ អនុវិស័យ ឬ សកម្មភាព ដែលកំណត់នៅក្នុងកម្មវិធី នៃឧបសម្ព័ន្ធ (II) បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ភាគីជាប់កិច្ចសន្យា ត្រូវធ្វើឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន មុននឹងអនុវត្តនូវវិធានការ ដែលបាន ធ្វើវិសោធនកម្ម ឬកែប្រែ ឬវិធានការថ្មី ឬវិធានការកំហិតបន្ថែម ឬនៅក្នុង កាលៈទេសៈពិសេសនូវ

(ក) ការជូនដំណឹងដល់ភាគីជាប់កិច្ចសន្យាម្ខាងទៀតពីព័ត៌មានលំអិតនៃការធ្វើ វិសោធនកម្ម ការកែប្រែ ឬ វិធានការនោះ

(ខ) ទទួលយកនៅពេលមានសំណើរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត នូវការ ពិគ្រោះយោបល់ដោយស្មោះត្រង់ជាមួយភាគីម្ខាងទៀតក្នុងទស្សនៈសម្រេចឱ្យ បាននូវការពេញចិត្តទៅវិញទៅមក។

៥ ភាគីនិមួយៗត្រូវប្រឹងប្រែងរៀងៗខ្លួនតាមពេលវេលាសមស្រប ដើម្បីកាត់បន្ថយ ឬ លុបចោលការរក្សាទុកទាំងឡាយ ដែលមានចែងក្នុងកម្មវិធីនៃឧបសម្ព័ន្ធ (I) និង (II)។

៦ មាត្រា ២ - ៣ និង ៦ មិនអនុវត្តចំពោះវិធានការណាមួយដែលគ្របដណ្តប់ដោយ ការលើកលែង ឬ ការទទួលបាននូវបដិប្បញ្ញត្តិដែលជាកាតព្វកិច្ចចែងក្នុងមាត្រា ៣ និង ៤ នៃកិច្ចព្រមព្រៀង TRIPS ដូចមានកំណត់ដោយឡែក នៅក្នុងមាត្រា ៣ ដល់ ៥ នៃកិច្ចព្រមព្រៀង TRIPS ឡើយ។

៧ មាត្រា ២ - ៣ និង ៦ មិនអនុវត្តចំពោះវិធានការណាមួយដែលភាគីជាប់កិច្ចសន្យាបានអនុម័ត ឬ រក្សាទុកចំពោះការធ្វើលទ្ធកម្មរបស់រដ្ឋាភិបាលឡើយ ។

## មាត្រា ៨

១- ភាគីជាប់កិច្ចសន្យានីមួយៗត្រូវធ្វើការផ្សព្វផ្សាយជាប្រញាប់ ឬ បើមិនដូចនេះទេត្រូវប្រកាសឱ្យបានដឹងជាសាធារណៈនូវច្បាប់ បទប្បញ្ញត្តិ បែបបទរដ្ឋបាល វិធានរដ្ឋបាល និង សេចក្តីសំរេចរបស់តុលាការរបស់ខ្លួន ស្តីពីការអនុវត្តជាទូទៅ ក៏ដូចជាកិច្ចព្រមព្រៀងអន្តរជាតិនានាដែលមានទំនាក់ទំនង ឬ ដែលមានឥទ្ធិពលដល់សកម្មភាពវិនិយោគ ។

២- នៅពេលដែលមានការស្នើសុំដោយភាគីជាប់កិច្ចសន្យាម្ខាងទៀត ភាគីជាប់កិច្ចសន្យានីមួយៗត្រូវធ្វើការឆ្លើយតបភ្លាមៗ ចំពោះសំនួរដោយឡែកៗដែលបានលើកឡើង និង ក្នុងករណីភាគីជាប់កិច្ចសន្យាម្ខាងទៀតផ្តល់ឱ្យនូវព័ត៌មានពាក់ព័ន្ធបញ្ហាដូចមានកំណត់ក្នុងកថាខ័ណ្ឌទី ១ ខាងលើ រួមបញ្ចូលទាំងបញ្ហាពាក់ព័ន្ធទៅនឹងកិច្ចសន្យា ដែលភាគីជាប់កិច្ចសន្យានីមួយៗត្រូវចូលរួមចំពោះការងារវិនិយោគ ។

៣- បទប្បញ្ញត្តិនៃកថាខ័ណ្ឌ ១ និង ២ នៃមាត្រានេះ មិនត្រូវបានបកស្រាយថាជាការចាប់បង្ខំឱ្យភាគីជាប់កិច្ចសន្យាណាមួយក្នុងការផ្សព្វផ្សាយព័ត៌មានសម្ងាត់នោះទេ ។ ការបើកចំហរនៃព័ត៌មាននឹងបន្ទុចបង្អាក់ដល់ការអនុវត្តច្បាប់ ឬ បើមិនដូចនេះទេ វានឹងមានលក្ខណៈផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ឬ វាអាចធ្វើឱ្យខូចខាតដល់ផលប្រយោជន៍បុគ្គល ឬ ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់ទៀតផង ។

## មាត្រា ៩

រដ្ឋាភិបាលនៃភាគីជាប់កិច្ចសន្យានីមួយៗដោយអនុលោមទៅតាមច្បាប់ និង បទប្បញ្ញត្តិរបស់ខ្លួន ត្រូវប្រឹងប្រែងផ្តល់នូវពេលវេលាដ៏សមស្របសំរាប់ទទួលបាននូវការផ្តល់មតិពីសាធារណជន មុនពេលធ្វើការអនុម័ត ធ្វើវិសោធនកម្ម ឬ លុបចេញនូវបទប្បញ្ញត្តិស្តីពីការអនុវត្តជាទូទៅ ដែលមានឥទ្ធិពលចំពោះបញ្ហាណាមួយដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ លើកលែងតែក្នុងករណីមានភាពបន្ទាន់ ឬដោយហេតុផលនៃស្ថានភាពគ្រោះអាសន្នតូចតាច (Purely minor nature )។

## មាត្រា ១០

ភាគីជាប់កិច្ចសន្យានីមួយៗត្រូវធានាថា វិធានការនឹងការប្រឹងប្រែងត្រូវបានធ្វើឡើងក្នុងការបង្ការ និង ប្រឆាំងអំពើពុករលួយទាក់ទងដល់បញ្ហាដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ ស្របទៅតាមច្បាប់នៃបទប្បញ្ញត្តិរបស់ខ្លួន។

## មាត្រា ១១

ភាគីជាប់កិច្ចសន្យានិមួយៗ ដោយអនុលោមទៅតាមច្បាប់ និង បទប្បញ្ញត្តិជាធរមានរបស់ខ្លួន ត្រូវធ្វើការពិចារណាប្រកបដោយសមានចិត្តចំពោះការដាក់ពាក្យសុំចូលស្នាក់នៅជាបណ្តោះអាសន្ន ឬ ការតាំងលំនៅដ្ឋានរបស់រូបវ័ន្តបុគ្គលមានសញ្ជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលមានបំណងចូលទៅក្នុងទឹកដីរបស់ខ្លួន ហើយរស់នៅទីនោះដើម្បីធ្វើសកម្មភាពវិនិយោគ។

## មាត្រា ១២

១- មិនមានភាគីជាប់កិច្ចសន្យាណាមួយអាចធ្វើការដកហូត ឬ ធ្វើជាតិតូបនីយកម្មលើការវិនិយោគរបស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនៅក្នុងតំបន់របស់ខ្លួន ឬប្រកាន់យកនូវវិធានការណាមួយដែលសមមូលទៅនឹងការដកហូត ឬការធ្វើជាតិតូបនីយកម្មបានឡើយ (ចាប់ពីពេលនេះតទៅហៅថាការដកហូត) លើកលែងតែ : (ក) ដើម្បីគោលបំណងសាធារណៈ (ខ) ដោយមិនមានការរើសអើង (គ) ទទួលបាននូវការទូទាត់សងយ៉ាងឆាប់រហ័ស គ្រប់ចំនួន និង មានប្រសិទ្ធិភាពដោយអនុលោមទៅតាមកថាខ័ណ្ឌ ២-៣ និង ៤ និង (គ) ស្របទៅតាមនីតិវិធីនៃច្បាប់ និង ស្របតាមមាត្រា ៤ ។

២- សំណងត្រូវមានទឹកប្រាក់ស្មើនឹងតម្លៃត្រឹមត្រូវរបស់ទីផ្សារនៃវិនិយោគ ដែលបានដកហូតនៅពេលការដកហូតបានប្រកាសឱ្យដឹងជាសាធារណៈ ឬ នៅពេលធ្វើការដកហូតតាមជម្រើសណាមួយដែលឆាប់ជាង ។ តម្លៃទីផ្សារដ៏ត្រឹមត្រូវ មិនត្រូវជះឥទ្ធិពលទៅលើ

ការប្រែប្រួលណាមួយនូវតម្លៃដែលកើតមាន ដោយមូលហេតុនៃការដកហូតនោះត្រូវបាន ប្រកាសឱ្យដឹងជាសាធារណៈមុនឡើយ។

៣- សំណងត្រូវបានទូទាត់ដោយមិនមានការពន្យាពេល ហើយត្រូវប្លូកបញ្ចូលផងដែរនូវការប្រាក់តាមអត្រាពាណិជ្ជកម្មសមស្រប ដោយគណនាទៅតាមរយៈពេលដកហូតរហូតដល់ពេលទូទាត់សង ។ សំណងបែបនេះត្រូវមានប្រសិទ្ធិភាព និង ផ្ទេរបានដោយសេរី និង អាចប្តូរបានដោយសេរីទៅជារូបិយវត្ថុនៃភាគីជាប់កិច្ចសន្យា នៃអ្នកវិនិយោគពាក់ព័ន្ធ ព្រមទាំងប្តូរបានដោយសេរីជារូបិយវត្ថុដែលអាចប្រើបាន ដូចមាននិយមន័យនៅក្នុងប្រការនៃកិច្ចព្រមព្រៀងស្តីពីមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលអាចត្រូវធ្វើវិសោធនកម្ម តាមអត្រាប្តូរប្រាក់លើទីផ្សារនៅថ្ងៃដកហូត។

៤- ដោយមិនមានផលប៉ះពាល់ទៅនឹងបញ្ញត្តិនៃប្រការ ១៧ អ្នកវិនិយោគដែលទទួលរងការខូចខាតដោយការដកហូត មានសិទ្ធិដាក់ពាក្យបណ្តឹងទៅតុលាការយុត្តិធម៌ ឬ តុលាការរដ្ឋបាល ឬភ្នាក់ងារនៃភាគីជាប់កិច្ចសន្យាទទួលបន្ទុកធ្វើការដកហូត ដើម្បីស្វែងរកការពិនិត្យឡើងវិញជាបន្ទាន់ចំពោះករណីរបស់អ្នកវិនិយោគនោះ និង ទឹកប្រាក់នៃសំណង ស្របទៅតាមគោលការណ៍ដែលកំណត់នៅក្នុងមាត្រានេះ។

## មាត្រា ១៣

ភាគីជាប់កិច្ចសន្យានីមួយៗត្រូវយល់ព្រមផ្តល់ដល់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតដែលទទួលរងនូវការខាតបង់ ឬខូចខាតដល់ការវិនិយោគរបស់គេនៅក្នុងតំបន់របស់ខ្លួន ដោយមូលហេតុមកពីជំលោះអាវុធ ឬ ការប្រកាសប្រទេសជាតិស្ថិតក្នុងភាពមានអាសន្នដូចជាការធ្វើបដិវត្តន៍ កុប្បកម្ម ភាពចលាចលស៊ីវិលឬហេតុការណ៍ប្រហាក់ប្រហែលនៅក្នុងតំបន់នៃភាគីជាប់កិច្ចសន្យានោះ នូវប្រព្រឹត្តិកម្មចំពោះការធ្វើឱ្យដូចដើមវិញការប៉ះប៉ូវសំណង ការទូទាត់សង ឬ ដំណោះស្រាយផ្សេងទៀតដែលមានភាពអនុគ្រោះមិនតិចជាងអ្វីដែលខ្លួនបានយល់ព្រមចំពោះអ្នកវិនិយោគរបស់ខ្លួន ឬអ្នកវិនិយោគនៃភាគីមិនជាប់កិច្ចសន្យាដោយជ្រើសរើសនូវភាពអនុគ្រោះណាមួយដែលប្រសើរជាង សំរាប់ផ្តល់ទៅអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

២. ការទូទាត់សងណាមួយ ដែលជាមធ្យោបាយនៃការដោះស្រាយ ដូចមានចែងនៅក្នុងកថាខ័ណ្ឌ ១ ត្រូវតែមានប្រសិទ្ធភាព អាចផ្ទេរបានដោយសេរី និង អាចប្តូរបានដោយសេរីតាមអត្រាប្តូរប្រាក់ទីផ្សារ ទៅជារូបិយវត្ថុនៃភាគីជាប់កិច្ចសន្យារបស់អ្នកវិនិយោគដែលមានការពាក់ព័ន្ធ និង ជារូបិយវត្ថុដែលអាចប្រើបានដោយសេរី ។

## មាត្រា ១៤

ប្រសិនបើភាគីជាប់កិច្ចសន្យា ឬ ភ្នាក់ងាររបស់ខ្លួនដែលបានតែងតាំងឱ្យធ្វើការទូទាត់សងទៅអ្នកវិនិយោគណាមួយនៃភាគីជាប់កិច្ចសន្យា ក្រោមរូបភាពជាការប៉ះប៉ូវសំណងការធានា ឬ កិច្ចសន្យាធានារ៉ាប់រង ទាក់ទងទៅនឹងការវិនិយោគនៃអ្នកវិនិយោគនោះនៅក្នុងតំបន់នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ភាគីជាប់កិច្ចសន្យាជាម្ចាស់ផ្ទះត្រូវទទួលស្គាល់ការផ្ទេរសិទ្ធ របស់ភាគីជាប់កិច្ចសន្យារបស់អ្នកវិនិយោគនោះ ឬសិទ្ធិរបស់ភ្នាក់ងារដែលគេបានតែងតាំង ឬការទាមទារណាមួយនៃអ្នកវិនិយោគនោះ ដែលការទូទាត់សងត្រូវបានអនុវត្ត ហើយត្រូវទទួលស្គាល់នូវសិទ្ធិនៃភាគីជាប់កិច្ចសន្យារបស់អ្នកវិនិយោគ ឬភ្នាក់ងាររបស់គេដែលបានតែងតាំងក្នុងការប្រតិបត្តិការងារដោយផ្អែកទៅលើឧបាទ្ទេសកម្មនូវសិទ្ធិ ឬការទាមទារណាមួយដូចនេះ ដូចគ្នាទៅនឹងសិទ្ធិ ឬការទាមទារដែលមានពីដើមមករបស់អ្នកវិនិយោគដែរ ។ ចំពោះការទូទាត់សងដែលនឹងត្រូវអនុវត្តចំពោះភាគីជាប់កិច្ចសន្យារបស់អ្នកវិនិយោគ ឬ ភ្នាក់ងាររបស់គេដែលបានតែងតាំងឱ្យទទួលសិទ្ធិ ឬ ការទាមទារ និងការផ្ទេរសិទ្ធឱ្យធ្វើការទូទាត់សំណងនេះ បញ្ញត្តិនៃមាត្រា ១២ - ១៣ និង ១៥ ក៏ត្រូវអនុវត្តតាមលំនាំដូចគ្នាយ៉ាងនោះដែរ។

## មាត្រា ១៥

១- ភាគីជាប់កិច្ចសន្យានិមួយៗត្រូវធានាថា រាល់ការផ្ទេរទាំងឡាយទាក់ទងទៅនឹងការវិនិយោគនៅក្នុងតំបន់របស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត អាចធ្វើការផ្ទេរចូលនិងផ្ទេរចេញដោយសេរីពីតំបន់ដោយពុំមានពន្យាពេលឡើយ ។ ការផ្ទេរដូចនេះត្រូវរួមបញ្ចូលជាពិសេសតែមិនកំណត់ត្រឹមនេះនូវ :

(ក) មូលធនដំបូង និង ទឹកប្រាក់បន្ថែមដើម្បីគាំពារ ឬបង្កើនការវិនិយោគ

(ខ) ប្រាក់ចំណេញ ការប្រាក់ ចំណេញមូលធន ប្រាក់ចំណេញនៃភាគហ៊ុន សួយសារ និង ថ្លៃឈ្នួល ព្រមទាំងចំណូលផ្សេងៗទៀតដែលទទួលបានក្នុងរយៈពេលធ្វើការវិនិយោគ។

(គ) ការទូទាត់តាមរយៈកិច្ចសន្យា រួមបញ្ចូលទាំងការសងប្រាក់កម្ចី ទាក់ទងនិងការវិនិយោគ

(ឃ) ប្រាក់ចំណូលទាំងអស់ ឬ មួយផ្នែកនៃការលក់ ឬ ការរំលាយការវិនិយោគ

(ង) ប្រាក់ចំណូល និង ប្រាក់បៀវត្សនៃបុគ្គលិកដែលបានមកពីភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលធ្វើការងារទាក់ទងទៅនឹងការវិនិយោគនៅក្នុងតំបន់នៃភាគីជាប់កិច្ចសន្យាជាម្ចាស់ផ្ទះ។

(ច) ការទូទាត់ដែលបានធ្វើឡើង ដោយអនុលោមទៅតាមមាត្រា ១២ និង ១៣

(ឆ) ការទូទាត់ដែលកើតមានឡើងពីដំណោះស្រាយវិវាទតាមមាត្រា ១៧។

២- ភាគីជាប់កិច្ចសន្យានិមួយៗត្រូវធានាបន្ថែមទៀតថា ការផ្ទេរនេះអាចធ្វើបាន ដោយពុំមានការពន្យាពេល ជារូបិយវត្ថុដែលប្រើបានដោយសេរី តាមអត្រាប្តូរប្រាក់លើទីផ្សារនៅថ្ងៃផ្ទេរ។

៣- ថ្វីបើមានចែងក្នុងកថាខ័ណ្ឌ ១ និង ២ ខាងលើក៏ដោយ ភាគីជាប់កិច្ចសន្យាអាចពន្យាពេល ឬ ផ្អាកនូវការផ្ទេរ ដោយអនុវត្តច្បាប់របស់ខ្លួន ប្រកបដោយយុត្តិធម៌ពុំមានការរើសអើង និង ក្នុងបំណងល្អទាក់ទងទៅនឹង :

(ក) ការក្ស័យធន ភាពមិនបានសង ឬការការពារសិទ្ធិនៃកូនបំណុល។

(ខ) ការបញ្ចេញ ការធ្វើពាណិជ្ជកម្ម ឬការលក់ដូរ ជាសញ្ញាប័ណ្ណធានា

(គ) កាចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬបទឧក្រិដ្ឋ ឬ

(ឃ) ការធានាដើម្បីអនុវត្តឱ្យស្របទៅនឹងបទបញ្ជា ឬដំណើរការនៅក្នុងនីតិវិធីនៃការវិនិច្ឆ័យទោស ។

## មាត្រា ១៦

១- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវយល់ព្រមប្រកបដោយសមានចិត្ត និងត្រូវផ្តល់នូវកាលានុវត្តភាពគ្រប់គ្រាន់សំរាប់បង្ករឱ្យមានការពិគ្រោះយោបល់ទាក់ទង ដល់ភាពជាតំណាងនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដើម្បីអាចស្នើឡើងនូវបញ្ហាណាមួយដែលប៉ះពាល់ដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ។

២- វិវាទរវាងភាគីជាប់កិច្ចសន្យាទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ ដែលដំណោះស្រាយតាមផ្លូវការទូតមិនទទួលបានការពេញចិត្តនោះ ត្រូវបញ្ជូនសុំការសំរេចពីក្រុមប្រឹក្សាមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល ត្រូវមានសមាសភាពអាជ្ញាកណ្តាលបីរូប ដែលភាគីជាប់កិច្ចសន្យានិមួយៗត្រូវតែងតាំងអាជ្ញាកណ្តាលមួយរូបនៅក្នុងអំឡុងពេលសាមសិបថ្ងៃ បន្ទាប់ពីថ្ងៃទទួលបាននូវសំណើស្នើសុំឱ្យមានការកាត់ក្តី ពីមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាលសម្រាប់វិវាទនោះ ហើយអាជ្ញាកណ្តាលទីបីនឹងត្រូវបានឯកភាព ដោយអាជ្ញាកណ្តាលទាំងពីរឱ្យធ្វើជាប្រធាន ក្នុងរយៈពេលសាមសិបថ្ងៃបន្ថែមទៀត ក្នុងករណីអាជ្ញាកណ្តាលទីបីនេះ ពុំមែនជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយឡើយ។

៣- ប្រសិនបើអាជ្ញាកណ្តាលទី៣ មិនត្រូវបានយល់ព្រមនៅពេលនោះពីសំណាក់អាជ្ញាកណ្តាលទាំងពីរដែលបានតែងតាំងដោយភាគីជាប់កិច្ចសន្យានីមួយៗ នៅក្នុងរយៈពេលសាមសិបថ្ងៃបន្ថែមដូចមានចែងក្នុងកថាខ័ណ្ឌ២ខាងលើទេនោះ ភាគីជាប់កិច្ចសន្យាទាំងពីរត្រូវលើកសំណើទៅប្រធានតុលាការយុត្តិធម៌អន្តរជាតិដើម្បីធ្វើការតែងតាំងអាជ្ញាកណ្តាលទីបីដែលពុំមែនជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយនោះឡើយ ។

៤- ក្រុមប្រឹក្សាមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល ត្រូវធ្វើការសំរេចក្តី ដោយបោះឆ្នោតយកសំឡេងភាគច្រើននៅក្នុងកាលបរិច្ឆេទសមស្របណាមួយ ។ សេចក្តីសំរេចនេះត្រូវចាត់ទុកថាជាសេចក្តីចុងក្រោយ និង ត្រូវបានអនុវត្តដោយភាគីទាំងពីរ ។

៥- ភាគីជាប់កិច្ចសន្យានីមួយៗត្រូវទទួលបន្ទុកលើការចំណាយចំពោះអាជ្ញាកណ្តាល និងតំណាងរបស់ខ្លួននៅក្នុងដំណើរការនៃការធ្វើមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល ។ ចំណាយរបស់ប្រធាន

នៃមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល នៅក្នុងការបំពេញកិច្ចការរបស់ខ្លួន និង ប្រាក់ចំណាយដែលនៅសេសសល់របស់ក្រុមប្រឹក្សាមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល គឺជាបន្ទុកដែលត្រូវចេញចំណាយស្មើគ្នារបស់ភាគីជាប់កិច្ចសន្យា។

## មាត្រា ១៧

១- សំរាប់គោលបំណងនៃមាត្រានេះ វិវាទវិនិយោគគឺជាវិវាទរវាងភាគីជាប់កិច្ចសន្យាជាមួយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលបាននាំឱ្យមាននូវការខាតបង់ ឬខូចខាតដោយមូលហេតុនៃ ឬ បានកើតឡើងពីការអនុវត្តរំលោភទៅលើសិទ្ធិដែលបានប្រទានឱ្យដោយកិច្ចព្រមព្រៀងនេះ ដល់ការវិនិយោគនៃអ្នកវិនិយោគរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត។

២- ពុំមានអ្វីនៅក្នុងមាត្រានេះ ត្រូវបានបកស្រាយថាជាការរារាំងអ្នកវិនិយោគដែលជាភាគីនៃវិវាទវិនិយោគ (ចាប់ពីពេលនេះតទៅនៅក្នុងមាត្រានេះហៅថា អ្នកវិនិយោគមានវិវាទ) ក្នុងការស្វែងរកដំណោះស្រាយផ្នែករដ្ឋបាល ឬ តុលាការនៅក្នុងតំបន់នៃភាគីជាប់កិច្ចសន្យា ដែលជាភាគីនៃវិវាទវិនិយោគនោះឡើយ (ចាប់ពីពេលនេះទៅនៅក្នុងមាត្រានេះហៅថា ភាគីវិវាទ) ។

៣- វិវាទវិនិយោគត្រូវបានដោះស្រាយទៅតាមលទ្ធភាពដែលអាចធ្វើបាន ក្នុងលក្ខណៈជាមិត្តភាពតាមរយៈការពិគ្រោះយោបល់ ឬ ការចរចារវាងអ្នកវិនិយោគមានវិវាទ និង ភាគីវិវាទ (ចាប់ពីនេះតទៅនៅក្នុងមាត្រានេះហៅថា "ភាគីដែលមានវិវាទ")។

៤- (ក)-ប្រសិនបើវិវាទវិនិយោគពុំអាចដោះស្រាយបានតាមរយៈការពិគ្រោះយោបល់ឬការចរចារ អ្នកវិនិយោគមានវិវាទ អាចលើកករណីនៃវិវាទវិនិយោគនោះតាមជម្រើសណាមួយដូចខាងក្រោមទៅ :

(i) តុលាការមានសមត្ថកិច្ចយុត្តិធម៌ ឬ តុលាការរដ្ឋបាល ឬ ភ្នាក់ងារនានានៅក្នុងតំបន់នៃភាគីវិវាទ

(ii) ធ្វើការផ្សះផ្សារ ឬ មជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល ស្របទៅតាមអនុសញ្ញាស្តីពីការដោះស្រាយវិវាទវិនិយោគរវាងរដ្ឋ និង ជនជាតិនៃរដ្ឋផ្សេងទៀតហើយដែលអាចត្រូវធ្វើវិសោធនកម្ម (ចាប់ពីពេលនេះតទៅនៅក្នុងមាត្រានេះហៅថា អនុសញ្ញា ICSID ) ក្នុងពេលដែលអនុសញ្ញានេះ នៅមានសុពលភាពជាធរមានរវាងភាគីជាប់កិច្ចសន្យា

(iii) ការផ្សះផ្សារឬមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល ក្រោមវិធានរចនាសម្ព័ន្ធបន្ថែមនៃមជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកដោះស្រាយវិវាទវិនិយោគ ដែលអាចត្រូវធ្វើវិសោធនកម្ម ក្នុងពេលដែលអនុសញ្ញា ICSID មិនមានសុពលភាពជាធរមានសំរាប់ភាគីជាប់កិច្ចសន្យា

(iv) មជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល នៅក្រោមវិធាននៃអាជ្ញាកណ្តាលរបស់គណៈកម្មការសហប្រជាជាតិ ស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិដែលអាចត្រូវធ្វើវិសោធនកម្ម និង

(v) អាជ្ញាកណ្តាលណាមួយ ដោយអនុលោមទៅនឹងវិធានមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាលផ្សេងទៀត ប្រសិនបើមានការយល់ព្រមពីភាគីវិវាទ ។

(ខ)-សំរាប់គោលបំណងនៃកថាខ័ណ្ឌ ៤(ក) ខាងលើ ប្រសិនបើអ្នកវិនិយោគមានវិវាទលើកករណីវិវាទវិនិយោគដើម្បីស្វែងរកការផ្សះផ្សារ ឬ មជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាលក្រោមអនុកថាខណ្ឌ (ii), (iii), (iv) និង (v) យ៉ាងតិចរយៈពេលបីខែត្រូវបានកន្លងផុតទៅ មុនអ្នកវិនិយោគមានវិវាទបានលើកសំណើសុំឱ្យមានការពិគ្រោះយោបល់ ឬ ការចរចារជាលាយលក្ខណ៍អក្សរ ។

៥- វិធានមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាលសំរាប់អនុវត្ត ត្រូវគ្រប់គ្រងអាជ្ញាកណ្តាលដូចបានកំណត់នៅក្នុងកថាខ័ណ្ឌ ៤ លើកលែងតែមានការកែតម្រូវនៅក្នុងមាត្រានេះ។

៦- អ្នកវិនិយោគមានវិវាទដែលមានបំណងចង់លើកករណីវិវាទវិនិយោគទៅធ្វើការចរចារ ឬ មជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាលដោយផ្អែកតាមកថាខ័ណ្ឌ ៤ ត្រូវផ្តល់ដល់ភាគីវិវាទនូវការ

ជូនដំណឹងជាលាយលក្ខណ៍អក្សរពីបំណងរបស់ខ្លួនយ៉ាងតិចណាស់ ៩០ថ្ងៃ មុនការតវ៉ាត្រូវបានស្នើឡើង ។ សេចក្តីជូនដំណឹងពីបំណងត្រូវបញ្ជាក់ :

(ក)- ឈ្មោះ អាស័យដ្ឋាននៃអ្នកវិនិយោគមានវិវាទ

(ខ)- បញ្ជាក់ពីវិធានការរបស់ភាគីវិវាទចំពោះបញ្ហាដែលកើតមាន និង ការសង្ខេបពីការពិតនិងមូលដ្ឋានគតិយុត្តិនៃវិវាទវិនិយោគឱ្យបានគ្រប់គ្រាន់ ដើម្បីលើកបញ្ហាឱ្យបានច្បាស់លាស់ រួមបញ្ចូលទាំងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ ដែលនាំឱ្យកើតមាននូវការបំពានរំលោភ ។

(គ)- ការផ្សះផ្សារ ឬមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល ដូចមានកំណត់ក្នុងកថាខ័ណ្ឌ ៤ ដែលអ្នកវិនិយោគមានវិវាទនឹងត្រូវជ្រើសរើស

(ឃ)- សំណើឱ្យមានជំនួយ និង ការប៉ាន់ប្រមាណទឹកប្រាក់នៃការខូចខាតដែលបានទាមទារ ។

៧- (ក)- ភាគីជាប់កិច្ចសន្យានិមួយៗ យល់ព្រមក្នុងការលើកករណីវិវាទវិនិយោគដោយអ្នកវិនិយោគមានវិវាទទៅធ្វើការផ្សះផ្សារ ឬ ទៅមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាលដូចមានកំណត់ក្នុងកថាខ័ណ្ឌ ៤ ដែលអ្នកវិនិយោគមានវិវាទបានជ្រើសរើសរួចហើយ។

(ខ)- ការយល់ព្រមដែលកំណត់នៅក្នុងអនុកថាខ័ណ្ឌ(ក) និង ការលើកសំណើដោយអ្នកវិនិយោគមានវិវាទ នូវការទាមទារទៅមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល ត្រូវបំពេញឱ្យបានគ្រប់គ្រាន់តាមតម្រូវការនៃ :

(i) ជំពូក II នៃអនុសញ្ញា ICSID ឬ វិធានវចនាសម្ព័ន្ធបន្ថែមនៃមជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកដោះស្រាយវិវាទវិនិយោគ ដែលអាចត្រូវធ្វើវិសោធនកម្ម ដើម្បីទទួលបាននូវការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីភាគីដែលមានវិវាទ និង

(ii) មាត្រា II នៃអនុសញ្ញាស្តីពីការទទួលស្គាល់ និង ការអនុវត្តនូវសេចក្តីសំរេចរបស់មជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាលអន្តរជាតិ ដែលអាចត្រូវធ្វើវិសោធនកម្ម

រួច (ចាប់ពីពេលនេះតទៅហៅថា "អនុសញ្ញា New York") ដើម្បីទទួលបាននូវការព្រមព្រៀងជាលាយលក្ខណ៍អក្សរ។

៨- ថ្វីបើមានកំណត់ក្នុងកថាខ័ណ្ឌ ៧ ក៏ដោយ ពុំមានការតវ៉ាណាអាចត្រូវបានលើកឡើងទៅធ្វើការផ្សះផ្សារ ឬទៅមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល ដែលបានកំណត់នៅក្នុងថាខ័ណ្ឌ ៤ បានទេ ប្រសិនបើរយៈពេលលើសពីបីឆ្នាំបានកន្លងផុតទៅ គិតពីថ្ងៃដែលអ្នកវិនិយោគមានវិវាទបានទទួល ឬ ទទួលបានជាដំបូងសំរាប់ដំរើសណាមួយដែលឆាប់ជាង នូវដំណឹងថាអ្នកវិនិយោគមានវិវាទបានទទួលរងនូវការខាតបង់ ឬ ខូចខាតដូចមានចែងក្នុងកថាខ័ណ្ឌ ១ ។

៩- ថ្វីបើមានកំណត់ក្នុងកថាខ័ណ្ឌ ៤ ក៏ដោយ អ្នកវិនិយោគមានវិវាទអាចផ្តួចផ្តើម ឬបន្តនូវសកម្មភាពដើម្បីស្វែងរកការជួយចេញជាអធិបញ្ញាក្នុងចន្លោះពេលនេះ ដែលមិនពាក់ព័ន្ធទៅនឹងការទូទាត់សងនូវការខូចខាតទេ មុនករណីនេះទៅដល់តុលាការរដ្ឋបាល ឬភ្នាក់ងារ ឬតុលាការ យុត្តិធម៌ក្រោមច្បាប់នៃភាគីវិវាទ ។

១០- លើកលែងតែមានការយល់ព្រមផ្សេងទៀតពីភាគីដែលមានវិវាទ តុលាការអាជ្ញាកណ្តាលដែលបង្កើតឡើងតាមកថាខ័ណ្ឌ ៤ ត្រូវមានសមាសភាពអាជ្ញាកណ្តាលបីរូប ដោយអាជ្ញាកណ្តាលមួយរូប តែងតាំងដោយភាគីដែលមានវិវាទនីមួយៗ ហើយអាជ្ញាកណ្តាលទី៣ ដែលជាប្រធានអាជ្ញាកណ្តាលត្រូវបានតែងតាំងដោយមានការព្រមព្រៀងពីភាគីដែលមានវិវាទ។ ប្រសិនបើអ្នកវិនិយោគមានវិវាទ ឬភាគីមានវិវាទពុំបានតែងតាំងអាជ្ញាកណ្តាលម្នាក់ដទៃទៀតនៅក្នុងរយៈពេល ៦០ថ្ងៃ គិតពីថ្ងៃដែលវិវាទវិនិយោគបានលើកសំណើឡើងទៅមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល អគ្គលេខាធិការនៃមជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកដោះស្រាយជំលោះវិនិយោគ (ចាប់ពីពេលនេះទៅនៅក្នុងមាត្រានេះហៅថា "ICSID") អាចត្រូវបានស្នើដោយភាគីណាមួយនៃភាគីដែលមានវិវាទ ដើម្បីតែងតាំងអាជ្ញាកណ្តាលម្នាក់ ឬ អាជ្ញាកណ្តាល

ដីទៃទៀតដែលពុំទាន់បានតែងតាំងពីមជ្ឈត្តវិនិច្ឆ័យនៃ ICSID តាមតម្រូវការនៃកថាខ័ណ្ឌ ១១ និង ១២ ។

១១- លើកលែងតែមានការយល់ព្រមផ្សេងទៀតពីភាគីដែលមានវិវាទ អាជ្ញាកណ្តាលទី៣ មិនអាចជាជនជាតិ ឬមិនត្រូវមានលំនៅដ្ឋាននៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាណាមួយឡើយ ឬមិនត្រូវជាអ្នកបំរើការងារឱ្យភាគីដែលមានវិវាទណាមួយ ឬមិនត្រូវបានពាក់ព័ន្ធទៅនឹងវិវាទវិនិយោគនៅក្នុងសមត្ថកិច្ចណាមួយឡើយ ។

១២- ក្នុងករណីមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាលធ្វើឡើងដោយយោលទៅតាមកថាខ័ណ្ឌ ៤ ភាគីដែលមានវិវាទ និមួយៗអាចកំណត់រហូតដល់បីជនជាតិ ដែលខ្លួនមិនយល់ព្រមឱ្យធ្វើជាអាជ្ញាកណ្តាល ។ ក្នុងស្ថានភាពដូចនេះអគ្គលេខាធិការនៃ ICSID អាចត្រូវបានស្នើសុំមិនឱ្យមានការតែងតាំងជាអាជ្ញាកណ្តាលនូវជនណាមួយដែលជាជនជាតិដូចបានកំណត់ដោយភាគីដែលមានវិវាទ ។

១៣- លើកលែងតែមានការយល់ព្រមផ្សេងទៀតពីភាគីមានវិវាទ មជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាលត្រូវធ្វើនៅក្នុងប្រទេសដែលជាភាគីនៃអនុសញ្ញាទីក្រុងញូវយ៉ក ។

១៤- តុលាការអាជ្ញាកណ្តាល ដែលបានបង្កើតឡើងតាមកថាខ័ណ្ឌ ៤ ត្រូវសំរេចបញ្ហាវិវាទ ស្របទៅនឹងកិច្ចព្រមព្រៀងនេះ និងវិធានរបស់ច្បាប់អន្តរជាតិដែលកំពុងអនុវត្ត។

១៥- ភាគីវិវាទត្រូវប្រគល់ជូនទៅភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវ :

(ក) សេចក្តីជូនដំណឹងនៃការតវ៉ាដែលបានលើកសំណើទៅមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល ជាលាយលក្ខណ៍អក្សរមិនយឺតជាង ៣០ថ្ងៃ ក្រោយថ្ងៃដែលការតវ៉ាត្រូវបានលើកឡើង និង

(ខ) ថតចំលងនូវឯកសារតវ៉ាទាំងអស់ដែលបានដាក់ជូនមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល

១៦- ភាគីជាប់កិច្ចសន្យា ដែលមិនមែនជាភាគីវិវាទ អាចផ្ញើសំណើទៅតុលាការអាជ្ញាកណ្តាល នូវសំនួរនៃការបកស្រាយកិច្ចព្រមព្រៀងនេះ នៅពេលមានការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីដែលមានវិវាទ ។

១៧- តុលាការអាជ្ញាកណ្តាលអាចចេញបញ្ញាជាវិធានការក្នុងរយៈពេលចន្លោះនេះ លើការការពារដើម្បីរក្សានូវសិទ្ធិរបស់អ្នកវិនិយោគដែលមានវិវាទ ឬសំរួលនូវដំណើរការនៃនីតិវិធីអាជ្ញាកណ្តាល រួមបញ្ចូលទាំងបទបញ្ជាដើម្បីរក្សាទុកនូវភស្តុតាងក្នុងការកាន់កាប់ ឬត្រួតពិនិត្យរបស់ភាគីដែលមានវិវាទនិមួយៗ ។ តុលាការអាជ្ញាកណ្តាលមិនត្រូវចេញបញ្ញាដែលភ្ជាប់ ឬដាក់បង្គាប់នូវការអនុវត្តវិធានការដែលនាំដល់ការចោទថា មានការរំលោភដូចមានយោងនៅក្នុងកថាខ័ណ្ឌ១ ឡើយ។

១៨- សេចក្តីសំរេចរបស់តុលាការអាជ្ញាកណ្តាលត្រូវបញ្ចូល :

(ក) ការសន្និដ្ឋានថាតើមាន ឬគ្មានការរំលោភដោយភាគីវិវាទនូវកាតព្វកិច្ចណាមួយក្រោមកិច្ចព្រមព្រៀងនេះ ចំពោះអ្នកវិនិយោគដែលមានវិវាទនឹងការវិនិយោគរបស់គេ និង

(ខ) ការដោះស្រាយជាសំណង ប្រសិនបើមានការរំលោភ ។ ការដោះស្រាយត្រូវមានកំរិតចំពោះមួយផ្នែក ឬ ទាំងពីរផ្នែកដូចតទៅ :

(i) ការទូទាត់សងនូវការខូចខាតជាប្រាក់ និង ការប្រាក់ដែលកំពុងអនុវត្ត និង

(ii) ការធ្វើសងឱ្យដូចដើមវិញនូវទ្រព្យសម្បត្តិ ។ ក្នុងករណីដូចនេះ សេចក្តីសំរេចត្រូវមានល័ក្ខខ័ណ្ឌថា ភាគីវិវាទអាចទូទាត់សងការខូចខាតជាប្រាក់ និងការប្រាក់ដែលកំពុងអនុវត្តជំនួសឱ្យការសងឱ្យដូចដើមវិញ។

តម្លៃអាចត្រូវបានសំរេច ស្របទៅតាមវិធាននៃមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាលកំពុងអនុវត្ត

១៩- សេចក្តីសំរេចដែលបានដាក់ចេញ ដោយអនុលោមទៅនឹង កថាខណ្ឌ ១៨ ជាសេចក្តីសំរេចចុងក្រោយដែលភាគីមានវិវាទត្រូវតែអនុវត្តន៍ ។ ភាគីវិវាទត្រូវអនុវត្តដោយមិនមានការពន្យាពេលនូវរាល់បញ្ញត្តិនៃសេចក្តីសំរេច ដោយត្រូវផ្តល់ឱ្យមានការអនុវត្តសេចក្តីសំរេចនោះនៅក្នុងតំបន់របស់ខ្លួនស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។

២០- មិនមានភាគីជាប់កិច្ចសន្យាណាមួយអាចផ្តល់នូវការការពារផ្នែកការទូត ឬនាំទៅឱ្យមានការតវ៉ាអន្តរជាតិទាក់ទងទៅនឹងវិវាទវិនិយោគដែលភាគីជាប់កិច្ចសន្យាម្ខាងទៀត និងអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាដែលមានវិវាទបានយល់ព្រមរួចហើយថា លើកសំណើ ឬ បានដាក់សំណើរួចហើយទៅមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាលដែលបានកំណត់នៅក្នុងកថាខ័ណ្ឌ ៤ នោះបានឡើយ លើកលែងតែភាគីជាប់កិច្ចសន្យាម្ខាងទៀតខកខានមិនបានគោរព ឬ មិនបានបំពេញនូវល័ក្ខខ័ណ្ឌដែលសេចក្តីសំរេចបានដាក់ចេញសំរាប់វិវាទវិនិយោគនោះ ។ ការការពារផ្លូវការទូតនៅក្នុងគោលបំណងនៃកថាខ័ណ្ឌនេះ មិនត្រូវដាក់បញ្ចូលផងទេនូវការប្តូរយោបល់មិនផ្លូវការផ្នែកការទូត សំរាប់គោលបំណងតែមួយនៃការសំរួលដំណោះស្រាយវិវាទវិនិយោគ ។

## មាត្រា ១៨

១- សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ក្រៅពីមាត្រា ១៣ មាត្រា XX និង XXI នៃកិច្ចព្រមព្រៀងទូទៅស្តីពីអត្រាពន្ធគយ និង ពាណិជ្ជកម្ម ១៩៩៤ “GATT 1994” និងមាត្រា XIV និង XIV Bis នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មផ្នែកសេវាកម្មនៃឧបសម្ព័ន្ធ 1B នៃកិច្ចព្រមព្រៀង WTO (The GATS) ត្រូវបានរួមបញ្ចូល និង ក៏ជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះដូចគ្នាដែរ ។

២- ក្នុងករណីដែលភាគីជាប់កិច្ចសន្យាប្រកាន់យកនូវវិធានការណាមួយ ដោយអនុលោមទៅតាមកថាខ័ណ្ឌ១ ដែលមិនស្របទៅនឹងកាតព្វកិច្ចនៃកិច្ចព្រមព្រៀង លើកលែងតែមាត្រា១៣

ដែលមាត្រានេះនឹងត្រូវអនុវត្តក្រោយពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន ភាគីជាប់កិច្ចសន្យាត្រូវប្រឹងប្រែងដោយសមហេតុផលក្នុងការជូនដំណឹងទៅភាគី ជាប់កិច្ចសន្យាម្ខាងទៀតនូវការធ្វើអធិប្បាយអំពីវិធានការដូចនេះ មុនពេលដែលវិធានការត្រូវបានប្រកាន់យក ឬ តាមលទ្ធភាពឆាប់បំផុតដែលអាចធ្វើបាននៅពេលបន្ទាប់ ។

## មាត្រា ១៩

១- ភាគីជាប់កិច្ចសន្យាអាចអនុម័ត ឬ បំរុងទុកនូវវិធានការដែលមិនស្របទៅ នឹងកាតព្វកិច្ចរបស់ខ្លួននៅក្រោមមាត្រា ២ ទាក់ទងទៅនឹងការធ្វើចរាចរទុនឆ្លងកាត់ព្រំដែន និង មាត្រា ១៥ :

(ក) នៅក្នុងស្ថានភាពភាពធ្ងន់ធ្ងរនៃជញ្ជីងពាណិជ្ជកម្ម និង ការលំបាក ឬ គំរាមកំហែងផ្នែកហិរញ្ញវត្ថុពីខាងក្រៅ ។

(ខ) នៅក្នុងករណីដែលស្ថិតក្នុងកាលៈទេសៈពិសេស ដោយចលនាទុនបង្ករ ឬ គំរាមឱ្យបង្ករនូវការលំបាកធ្ងន់ធ្ងរ សំរាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ជាពិសេសនយោបាយគ្រប់គ្រងសាច់ប្រាក់ និង នយោបាយអត្រាប្តូរប្រាក់ ។

២- រាល់វិធានការដែលយោងទៅ នឹង កថាខ័ណ្ឌ ១ ខាងលើ :

(ក) ត្រូវតែមានសង្គតភាពជាមួយបណ្តាមាត្រានៃកិច្ចព្រមព្រៀងរបស់ មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលអាចត្រូវធ្វើវិសោធនកម្ម ល្គឹកណាភាគីជាប់កិច្ចសន្យាដែលប្រកាន់យកនូវវិធានការនោះជាភាគីនៃបណ្តាមាត្រាខាងលើ

(ខ) ពុំត្រូវប្រកាន់យកលើសពីតម្រូវការចាំបាច់ ក្នុងការដោះស្រាយជាមួយកាលៈទេសៈដូចបានកំណត់នៅក្នុងកថាខ័ណ្ឌ ១ ខាងលើ

(គ) ត្រូវបានប្រកាន់យកបណ្តោះអាសន្ន ហើយត្រូវបំបាត់ចេញឱ្យបានឆាប់បំផុតទៅតាមលក្ខខណ្ឌអនុញ្ញាត ។

(ឃ) ត្រូវបានជូនដំណឹងយ៉ាងប្រញ៉ាប់ទៅភាគីជាប់កិច្ចសន្យាម្ខាងទៀត និង

(ង) ត្រូវបញ្ចៀសនូវការខូចខាតមិនចាំបាច់ចំពោះផលប្រយោជន៍ពាណិជ្ជកម្ម-សេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

៣- ពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបានយល់ឃើញថា ជាការកែប្រែនូវសិទ្ធិទទួលបាន និង កាតព្វកិច្ចត្រូវបំពេញរបស់ភាគីជាប់កិច្ចសន្យាដែលជាភាគីមួយនៃបណ្តាមាត្រានៃកិច្ចព្រមព្រៀងមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលអាចត្រូវបានធ្វើវិសោធនកម្មនោះឡើយ។

## មាត្រា ២០

១- ថ្វីបើមានបណ្តាបញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះក៏ដោយ ភាគីជាប់កិច្ចសន្យាមិនត្រូវបានរារាំង ក្នុងការប្រកាន់យកនូវវិធានការដែលទាក់ទងទៅនឹងសេវាកម្ម ហិរញ្ញវត្ថុដោយហេតុផលប្រុងប្រយ័ត្ន រួមបញ្ចូលទាំងវិធានការក្នុងការការពារអ្នកវិនិយោគ អ្នកដាក់ប្រាក់បញ្ញើរ អ្នកនយោបាយ ឬ ជនដែលមានតួនាទីជាម្ចាស់នៃសហគ្រាសដែលផ្តត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ ឬ ដើម្បីធានានូវបូរណភាព និង ស្ថេរភាពនៃប្រព័ន្ធហិរញ្ញវត្ថុរបស់ខ្លួនឡើយ។

២- ក្នុងករណីដែលភាគីជាប់កិច្ចសន្យាប្រកាន់យកនូវវិធានការណាមួយ ដោយយោងតាមកថាខ័ណ្ឌ ១ ខាងលើ ដែលវិធានការនោះមិនសមស្របទៅនឹងកាតព្វកិច្ចនៃបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ភាគីជាប់កិច្ចសន្យានោះ ពុំត្រូវប្រើនូវវិធានការដូចនេះដើម្បីធ្វើជាមធ្យោបាយក្នុងការបញ្ចៀសកាតព្វកិច្ចរបស់ខ្លួនឡើយ ។

## មាត្រា ២១

១- ពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយថា ជាការធ្វើបដិបញ្ញត្តិអំពីសិទ្ធិ និងកាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងពហុភាគីទាក់ទងទៅនឹងការការពារកម្មសិទ្ធិបញ្ញាដែលភាគីជាប់កិច្ចសន្យាជាភាគីនោះឡើយ ។

២- មិនមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដើម្បីបង្ខំភាគីជាប់កិច្ចសន្យាណាមួយក្នុងការផ្តល់បន្ថែមឱ្យអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និងការវិនិយោគរបស់គេនូវប្រព្រឹត្តិកម្មដែលបានយល់ព្រមឱ្យអ្នកវិនិយោគនៃភាគីមិនជាប់កិច្ចសន្យា និងការវិនិយោគរបស់គេ អាស្រ័យដោយហេតុផលនៃកិច្ចព្រមព្រៀងពហុភាគី ទាក់ទងទៅនឹងការការពារនូវកម្មសិទ្ធិបញ្ញា ដែលភាគីជាប់កិច្ចសន្យាជាម្ចាស់ផ្ទះជាភាគីនោះឡើយ ។

៣- ភាគីជាប់កិច្ចសន្យាត្រូវផ្តល់ជូននូវការពិចារណាដ៏សមរម្យ បំរើឱ្យការការពារយ៉ាងពេញលេញ និង មានប្រសិទ្ធិភាពនូវកម្មសិទ្ធិបញ្ញា ហើយត្រូវប្រញាប់ពិគ្រោះយោបល់ទៅវិញទៅមកចំពោះករណីនេះ តាមសំណើនៃភាគីជាប់កិច្ចសន្យាណាមួយ ។ យោងទៅតាមលទ្ធផលនៃការពិគ្រោះយោបល់ ភាគីជាប់កិច្ចសន្យានីមួយៗត្រូវប្រកាន់យកនូវវិធានការសមស្របដើម្បីដកចេញនូវកត្តាដែលបានទទួលស្គាល់ថា មានឥទ្ធិពលផ្ទុយទៅនឹងការវិនិយោគដោយអនុលោមទៅតាមច្បាប់ និង បទប្បញ្ញត្តិជាធរមានរបស់ខ្លួន ។

## មាត្រា ២២

១- មិនមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តសំរាប់វិធានការពន្ធដារទេ លើកលែងតែបានបញ្ជាក់នៅក្នុងកថាខ័ណ្ឌ ២ - ៣ និង ៤ នៃកិច្ចព្រមព្រៀងនេះ

២- មាត្រា ១ - ៥ - ៨ - ១២ - ២៥ និង ២៧ ត្រូវអនុវត្តចំពោះវិធានការពន្ធដារ

៣- មាត្រា ១៦ និង ១៧ ត្រូវអនុវត្តចំពោះវិវាទក្រោមកថាខ័ណ្ឌ ២ ខាងលើ

៤- មាត្រា ២៣ ត្រូវអនុវត្តចំពោះវិធានការពន្ធដារពាក់ព័ន្ធទៅនឹងបញ្ហា ដែលបានលើកឡើងនៅក្នុងកថាខ័ណ្ឌ ២ នៃមាត្រានេះ ។

## មាត្រា ២៣

១- ភាគីជាប់កិច្ចសន្យាត្រូវបង្កើតនូវគណៈកម្មាធិការចំរុះមួយ (ចាប់ពីពេលនេះតទៅហៅថា "គណកម្មាធិការ") ក្នុងទិសដៅបំពេញគោលបំណងនៃកិច្ចព្រមព្រៀងនេះ ។ មុខងារភារកិច្ចរបស់គណៈកម្មាធិការមាន :

(ក)- ពិភាក្សា និង ពិនិត្យឡើងវិញនូវការអនុវត្ត និងដំណើការនៃកិច្ចព្រមព្រៀងនេះ

(ខ)- ពិនិត្យឡើងវិញនូវវិធានការពិសេសដែលបានរក្សាទុក ធ្វើវិសោធន៍កម្ម កែប្រែ ឬ អនុម័ត ដោយអនុលោមទៅនឹងកថាខ័ណ្ឌ ១ នៃមាត្រា ៧ ដើម្បីគោលបំណងរួមចំណែកក្នុងការបន្ថយ ឬការលុបចេញនូវវិធានការពិសេសនោះ

(គ)- ពិភាក្សានូវវិធានការពិសេសដែលបានអនុម័ត ឬ រក្សាទុកដោយអនុលោមទៅតាមកថាខ័ណ្ឌ ២ នៃមាត្រា ៧ ក្នុងគោលបំណងជម្រុញលើកទឹកចិត្តនូវល័ក្ខខ័ណ្ឌអនុគ្រោះ សំរាប់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យា និង

(ឃ)- ពិភាក្សាបញ្ហាទាក់ទងនឹងការវិនិយោគដ៏ទៃទៀត ដែលមានការពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនេះ ។

២- គណៈកម្មាធិការ ក្នុងករណីចាំបាច់ អាចលើកជាអនុសាសន៍សមស្របដោយមានការឯកភាពគ្នា ជូនភាគីជាប់កិច្ចសន្យាដើម្បីញុាំងឱ្យដំណើរការរបស់គណៈកម្មាធិការកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត ឬការធ្វើឱ្យបានសំរេចនូវគោលដៅនៃកិច្ចព្រមព្រៀងនេះ ។

៣- គណៈកម្មាធិការត្រូវមានសមាសភាពរបស់អ្នកតំណាងនៃភាគីជាប់កិច្ចសន្យា។ គណៈកម្មាធិការត្រូវកំណត់នូវវិធាននៃនីតិវិធីផ្ទាល់ ក្នុងការបំពេញការងាររបស់ខ្លួន។

៤- គណៈកម្មាធិការអាចបង្កើតអនុ-គណៈកម្មាធិការ និងធ្វើប្រតិភូកម្មការងារដោយឡែកជូនអនុគណៈកម្មាធិការនេះ ។ គណៈកម្មាធិការ នៅពេលដែលមានការឯកភាពរបស់ភាគីជាប់កិច្ចសន្យា អាចរៀបចំឱ្យមានការប្រជុំរួមគ្នាជាមួយវិស័យឯកជន ។

៥- គណៈកម្មាធិការត្រូវជួបគ្នា នៅពេលមានសំណើរបស់ភាគីជាប់កិច្ចសន្យាណាមួយ ។

## មាត្រា ២៤

ភាគីជាប់កិច្ចសន្យាត្រូវទប់ស្កាត់នូវការលើកទឹកចិត្តលើការវិនិយោគរបស់អ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដោយវិធានការបន្ធូរបន្ថយផ្នែកបរិស្ថាន។ ក្នុងន័យនេះ ភាគីជាប់កិច្ចសន្យានីមួយៗ មិនត្រូវលះបង់សិទ្ធិ ឬ បើពុំនេះទេ អនុវត្តផ្ទុយទៅនឹងវិធានការបរិស្ថាននេះ ដូចជាការលើកទឹកចិត្តអោយបង្កើត ការទិញយក ឬ ការពង្រីកនៅក្នុងតំបន់វិនិយោគរបស់ខ្លួន ដោយអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនោះឡើយ។

## មាត្រា ២៥

ក្នុងការបំពេញនូវកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ ភាគីជាប់កិច្ចសន្យានិមួយៗត្រូវប្រកាន់យកនូវវិធានការសមហេតុផល ដែលអាចរកបាន ក្នុងការធានានូវការពិនិត្យកិច្ចព្រមព្រៀងនេះ ដោយរដ្ឋាភិបាលមូលដ្ឋាននៅក្នុងតំបន់របស់ខ្លួន ។

## មាត្រា ២៦

១- ភាគីជាប់កិច្ចសន្យាមួយ អាចបដិសេធនូវផលប្រយោជន៍ពីកិច្ចព្រមព្រៀងនេះចំពោះអ្នកវិនិយោគ នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលជាសហគ្រាសនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និង ចំពោះការវិនិយោគរបស់គេ ក្នុងករណីដែលសហគ្រាសនោះគឺជាកម្មសិទ្ធិ ឬ គ្រប់គ្រងដោយអ្នកវិនិយោគនៃភាគីមិនជាប់កិច្ចសន្យា ហើយភាគីជាប់កិច្ចសន្យាជាអ្នកបដិសេធ :

(ក) មិនបានរក្សានូវទំនាក់ទំនងការទូតជាមួយនៃភាគីមិនជាប់កិច្ចសន្យា ឬ

(ខ) អនុម័ត ឬរក្សាទុកនូវវិធានការ ចំពោះភាគីមិនជាប់កិច្ចសន្យាថា ហាមឃាត់ការធ្វើអាជីវកម្មជាមួយសហគ្រាស ឬត្រូវបានរំលោភ ឬបានបំភ័ន ក្នុងករណីដែលកិច្ចព្រមព្រៀងបានយល់ព្រមរួចហើយថា ឱ្យផលប្រយោជន៍ទៅឱ្យសហគ្រាស ឬការវិនិយោគរបស់សហគ្រាសនោះ ។

២- ដោយតម្រូវឱ្យមានការជូនដំណឹង និង មានការពិគ្រោះយោបល់ជាមុន ភាគីជាប់កិច្ចសន្យាអាចបដិសេធនូវផលប្រយោជន៍ដែលទទួលបានពីកិច្ចព្រមព្រៀងនេះទៅឱ្យអ្នកវិនិយោគនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតដែលជាសហគ្រាសនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និង ការវិនិយោគរបស់គេ ប្រសិនបើសហគ្រាសនោះគឺជាកម្មសិទ្ធិ ឬ គ្រប់គ្រងដោយអ្នកវិនិយោគនៃភាគីមិនជាប់កិច្ចសន្យា ហើយសហគ្រាសពុំមានសកម្មភាពធុរកិច្ចជាទ្រង់ទ្រាយធំនៅក្នុងតំបន់នៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនោះ។

## មាត្រា ២៧

១- កិច្ចព្រមព្រៀងនេះត្រូវបានចូលជាធរមាននៅក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយការបរិច្ឆេទនៃការប្តូរកំណត់ការទូត ដែលបានជូនដំណឹងទៅវិញទៅមកថា នីតិវិធីផ្លូវច្បាប់រៀងៗខ្លួនដែលជាតម្រូវការចាំបាច់សំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ បានបំពេញរួចរាល់ហើយ ។ កិច្ចព្រមព្រៀងនេះនឹងត្រូវមានតម្លៃជាធរមានសំរាប់រយៈពេល ដប់ឆ្នាំក្រោយការចូលជាធរមាន និង ត្រូវបន្តមានសុពលភាពជាធរមានរហូត លើកលែងតែមានការបញ្ចប់ដូចមានចែងនៅក្នុងកថាខ័ណ្ឌ ២ ខាងក្រោម ។ កិច្ចព្រមព្រៀងនេះក៏ត្រូវអនុវត្តផងដែរ ចំពោះគ្រប់ការវិនិយោគនៃអ្នកវិនិយោគ របស់ភាគីជាប់កិច្ចសន្យាណាមួយដែលបានធ្វើនៅក្នុងតំបន់នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ស្របទៅតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាននៃភាគីជាប់កិច្ចសន្យាម្ខាងទៀត មុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។

២- ភាគីជាប់កិច្ចសន្យាអាចបញ្ចប់កិច្ចព្រមព្រៀងនេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមួយឆ្នាំមុន ទៅភាគីជាប់កិច្ចសន្យាម្ខាងទៀត នៅពេលផុតកំណត់នៃរយៈពេលដប់ឆ្នាំដំបូង ឬ ពេលណាមួយក្រោយពេលនោះ ។

៣- ចំពោះការវិនិយោគដែលបានធ្វើមុនថ្ងៃបញ្ចប់កិច្ចព្រមព្រៀងនេះ បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវបន្តមានប្រសិទ្ធភាពរយៈពេលដប់ឆ្នាំ គិតចាប់ពីថ្ងៃបញ្ចប់កិច្ចព្រមព្រៀងនេះ ។

៤- កិច្ចព្រមព្រៀងនេះ មិនអនុវត្តចំពោះការទាមទារដែលកើតឡើង ឬការទាមទារដែលបានដោះស្រាយរួច មុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះឡើយ ។

៥- ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះគឺជាចំណែកទាំងស្រុងនៃកិច្ចព្រមព្រៀងនេះ។

ជាសក្ខីភាព អ្នកតំណាងស្របច្បាប់ដែលរដ្ឋាភិបាលរៀងៗខ្លួនបានប្រគល់អំណាចត្រឹមត្រូវ មានសិទ្ធិគ្រប់គ្រាន់ក្នុងការចុះហត្ថលេខា ។

កិច្ចព្រមព្រៀងនេះធ្វើឡើងចំនួន ០២ ច្បាប់ នៅទីក្រុងតូក្យូ ថ្ងៃទីដប់បួន ខែមិថុនា ឆ្នាំ ២០០៧ ជាភាសាអង់គ្លេស ។

**តំណាងព្រះរាជាណាចក្រកម្ពុជា** **តំណាងជប៉ុន**

**ហត្ថលេខា ហ៊ុន សែន** **ហត្ថលេខា ស៊ិនហ្ស៊ូ អាបេ**